មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCIM

cambodian center for independent media

ថ្ងៃទី ១១ ខែមិនា ឆ្នាំ ២០១៣

# កិច្ចសម្ភាសន៍ជាមួយលោកម៉ម សូណង់ដូ

---

លោក ម៉ម សូណង់ដូដែលជាអ្នកការពារសិទ្ធិមនុស្សកម្ពុជាគឺជាមនុស្សចុងក្រោយដែលទទួលពានរង្វាន់ Front Line Award 2013 ពីការការពារសិទ្ធិមនុស្សដែលកំពុងជួបហានិភ័យ។ក្នុងនាមជាអ្នកសារព័ត៌មាននិងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យលោកត្រូវបានគេចាប់ខ្លួនកាលដើមខែកក្កដាឆ្នាំ ២០១២ពីបទញុះញង់ការបះបោរនិងបំផុសឲ្យមានកំលាំងប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល។ អត្ថបទខាងក្រោមជាបទសម្ភាសន៍ដែលធ្វើឡើងជាមួយលោកម៉ម សូណង់ដូដែលថ្មីៗនេះគាត់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន២០ឆ្នាំ។

**សំណួរៈមុនពេលដែលលោកជាប់ទោសនេះតើលោកជួបហានិភ័យអ្វីខ្លះក្នុងការដឹកនាំការងាររបស់លោក**

**លោក សូណង់ដូៈ**ខ្ញុំចូលចិត្តការប្រថុយប្រថានហើយខ្ញុំពិតជាមានការភ្ញាក់ផ្អើលខ្លាំងណាស់ដែលខ្ញុំអាចរស់បានយូរ
ថ្នាក់នេះ។ ខ្ញុំភ្ញាក់ផ្អើលរាល់ព្រឹកដែលបាននៅមានជីវិត។ខ្ញុំទាយថាមានតែទេវតា ឬព្រះពុទ្ធទេដែលបានជួយថែរក្សាខ្ញុំរហូតមក។ តែសម្រាប់ខ្ញុំ កាន់តែគ្រោះថ្នាក់ កាន់តែគួរអោយរំភើប
ឲ្យតែបានជួយប្រជាជនកម្ពុជា។

ប្រជាធិបតេយ្យសិទ្ធិមនុស្សភាពយុត្តិធម៌.....អ្វីៗទាំងអស់បានសភាពអាក្រក់ខ្លាំងណាស់នៅកម្ពុជាដោយសារតែរដ្ឋាភិបាលរបស់យើង។ក្នុងនាមជាម្ចាស់ស្ថានីយវិទ្យុនិងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យវាពិតជាមានប្រយោជន៍ណាស់សម្រាប់សង្គម។ខ្ញុំដឹងថាវាគ្រោះថ្នាក់ហើយ ដឹងថាមនុស្សម្នាក់មិនអាចសង្គ្រោះពិភពលោកបានទេ។ តែអញ្ចឹងបើគ្មានអ្នកណាម្នាក់ចេញមុខតើមានអ្នកណាចេញមុខ? ខ្ញុំចង់បានប្រជាធិបតេយ្យនឹងក្តីសង្ឃឹមសម្រាប់ប្រជាជនកម្ពុជាជំនាន់ក្រោយ។

ខ្ញុំព្យាយាមធ្វើជាគំរូមួយសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ បន្ទាប់ពីរបបខ្មែរក្រហមប្រជាជនកម្ពុជាមានភាពភ័យខ្លាច តែក៏ចាប់ផ្តើមទាមទារប្រជាធិបតេយ្យដែរហើយនៅមានការគាំទ្រពីបរទេសផងដែរ។ខ្ញុំក៏បានធ្វើដែរ ហើយឥឡូវខ្ញុំត្រូវការប្រជាធិបតេយ្យសម្រាប់ប្រជាជនកម្ពុជា តែខ្ញុំចង់បានយុត្តិធម៌និង

ភាពស្មោះត្រង់ហើយខ្ញុំមិនគិតពីអំណាច
ឬផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីនោះទេ។ មិនអញ្ចឹងទេ ខ្ញុំមិនអាចប្រាប់ប្រជាជនកម្ពុជាឲ្យធ្វើតាមបានឡើយ។

**សំណួរ :តើអ្វីជំរុញឲ្យលោកបង្កើតស្ថានីយវិទ្យុហើយបន្តរហូតទៅជួបគ្រោះថ្នាក់នោះ?**

**លោក សួណង់ដួ:**ពិតណាស់ការទទួលបានអជ្ញាប័ណ្ណបើកស្ថានីយវិទ្យុនេះគឺជារឿងចៃដន្យប៉ុណ្ណោះ។ ខ្ញុំបានវាព្រោះតែប្អូនប្រុសខ្ញុំជាប់ទាក់ទងនឹងគណបក្សប្រជាជនកម្ពុជា។ ខ្ញុំមិនដែលចង់ធ្វើជាអ្នកនយោបាយទេ ខ្ញុំគ្រាន់តែចង់ផ្សព្វផ្សាយតន្ត្រីនិងបែបបទសង្គមបារាំងតិចតួចដែលខ្ញុំបានជួបប្រទះពេលខ្ញុំនៅទីនោះ ក្នុងទសវត្សរ៍១៩៦០។តែដោយសារតែពេលវេលាខ្ញុំបានផ្លាស់ប្តូរចិត្ត។ អ្នកនយោបាយកាន់អំណាចបានកុហកបោកប្រាសហើយប្រើអំណាចបំភ័យប្រជាជន។ខ្ញុំខ្ពើមរអើមជាមួយអ្វីដែលពួកគេនិយាយហើយនេះហើយជាហេតុផលដែលខ្ញុំចង់កែតម្រូវនូវអ្វីដែលពួកគេបានបង្ហាញ។ ខ្ញុំកើតទុក្ខដែលប្រជាជនកម្ពុជាត្រូវរស់ដោយជួបការលំបាកគ្មានប្រាក់ខែ។ពួកគេមានតែសិទ្ធិសំរាប់រស់តែគ្មានអ្វីផ្សេងទៀតនោះទេ។

**សំណួរ: ហេតុអ្វីបានជាលោកនិងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតក្លាយជាគោលដៅរបស់រដ្ឋាភិបាល?**

**លោក សួណង់ដួ:**

ខ្ញុំមិនដែលប្រៀបធៀបខ្លួនទៅកាន់អ្នកណានោះទេ។ខ្ញុំដឹងថាបើខ្ញុំជោគជ័យប្រជាជនកម្ពុជាក៏ជោគជ័យដែរ។ តែរដ្ឋាភិបាលចង់ក្លាយជាមនុស្សតែម្នាក់គត់ដែលធ្វើបែបនេះហើយគេមិនទទួលជំនួយពីអ្នកផ្សេងនោះទេ។ មនុស្សដែលនៅកំពូលគេចេះតែសំលាប់និងគំរាមកំហែងប៉ុណ្ណោះ។
សរុបមកពួកគេធ្វើការដូចជារបបកុម្មុយនីស្ត។សព្វថ្ងៃនេះទោះជាអ្នកចេះដឹង ដែលខ្ញុំសំដៅដល់អ្នកបញ្ចប់ការសិក្សាពីបរទេសគឺទោះពួកគេត្រឡប់មកប្រទេសវិញក៏ដោយ ក៏នៅខ្វះការជំរុញដើម្បីឲ្យពួកគេធ្វើការជួយប្រទេសដែរ។ ហើយបើខ្ញុំធ្វើដូចពួកគេនោះកម្ពុជានឹងមិនអាចស្រោចស្រង់បានទេ។ ខ្ញុំគ្រាន់តែសុំលិទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះ។

**សំណួរ : តើការផ្តល់ពានរង្វាន់ដល់លោកនៅកម្ពុជានេះនិងមានឥទ្ធិពលអ្វីខ្លះ? ទើឥទ្ធិពលអ្វីខ្លះដែលលោកសង្ឃឹមថានឹងមាន?**

**លោក សួណង់ដួ:** ការផ្តល់នេះនឹងមានឥទ្ធិពលមួយ ព្រោះពានរង្វាន់បែបនេះមិនធ្លាប់មានប្រជាជនណាម្នាក់ធ្លាប់ទទួលបានពីមុនមកនោះទេ។ ខ្ញុំមិនធ្លាប់គិតថាអាចត្រូវគេផ្តល់ឲ្យអញ្ចឹងនោះទេ។
នេះជាវិធីដើម្បីជំរុញទឹកចិត្តប្រជា
ជនកម្ពុជាឲ្យងើបឡើងការពារសិទ្ធិមនុស្ស។បើខ្ញុំមានវាវានិងបង្ហាញទៅប្រជាជនកម្ពុជាផ្សេងទៀតថាពិភពលោកទទួលស្គាល់យើងហើយ។

**សំណួរ: លោកបានជួយប្រជាជនកម្ពុជាក្រីក្រ។តើមេរៀនទាក់ទងនឹងសិទ្ធិមនុស្សអ្វីខ្លះដែលលោកបានសិក្សាពីសហគមន៍ទាំងនេ?**

**លោក សូណង់ដូ:** ពេលមានគេសំដៅមករកអ្នកអ្នកនឹងមានអារម្មណ៍ដឹងថាគេស្មោះត្រង់ឬអត់ប្រជាជនដែលខ្ញុំជួប
បង្ហាញដល់ខ្ញុំថាភាពស្មោះត្រង់ពិតជាសំខាន់ណាស់។ព្រោះខ្ញុំមានសច្ចភាពចំពោះពួកគេពួកគេឆ្លើយតបមកវិញដោយការជឿជាក់លើខ្ញុំ។ ខ្ញុំមានភាពខ្លាំងក្នុងខ្លួនហើយធ្វើអ្វីគ្រប់យ៉ាងដែលខ្ញុំបានសន្យាជាមួយពួកគេទោះជាខ្ញុំនៅជាប់ពន្ធនាគារក៏ដោយ។ខ្ញុំនៅតែបន្តរស់នៅតទៅទៀត៕